ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង : ៤៩/១០-វីង យីង

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: អ៊ឹង សុទ្ធី

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: លីវ សុវណ្ណា

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: គង់ ផល្លះ

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : ក្រុមហ៊ុន វីង យីង (ខេមបូឌា) ហ្គាមេន ហ្វាក់តើរី អិលធីឌី

អាសយដ្ឋាន : ភូមិព្រៃរកា ឃុំឆក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ : ០១២ ៧២៧ ៣០៤ ទូរសារ : គ្មាន

តំណាងភាគីនិយោជក : គ្មាន

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - សហព័ន្ធសហជីពយុវជនខ្មែរ

- សហជីពយុវជនខ្មែរក្រុមហ៊ុន វីង យីង

អាសយដ្ឋាន : ភូមិព្រៃរកា ឃុំឆក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល

លេខទូរស័ព្ទ : ០១៧ ៣៧០ ៣៦៣ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក ម៉ៃ វឌ្ឍនា មន្ត្រីសហព័ន្ធសហជីពយុវជនខ្មែរ

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

| | |
|---|---|
| ២- លោក ហង់ សុរិយា | អគ្គលេខាធិការសហព័ន្ធសហជីពយុវជនខ្មែរ |
| ៣- លោក អ៊ិត ស៊ីថា | ប្រធានសហជីពយុវជនខ្មែរក្រុមហ៊ុន វីង យីង |
| ៤- លោក ដុក ភក្តី | អនុប្រធានសហជីព |
| ៥- លោក សឿ ទូច | លេខាធិការសហជីព |
| ៦- លោក ឆាំង ឈាន់ | ទីប្រឹក្សាសហជីព |

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សុំឱ្យក្រុមហ៊ុនទទួលយកលោក ឆាំង ឈាន់ អត្តលេខ ៣៤៣៦ ដែលជាប្រធានសហជីពយុវជនខ្មែរឱ្យចូលបំរើការងារជាធម្មតាវិញ ដែលក្រុមហ៊ុនបញ្ឈប់មិនត្រឹមត្រូវតាមផ្លូវច្បាប់ ។

២- សុំឱ្យក្រុមហ៊ុនអនុញ្ញាតស្ត្រីមានផ្ទៃពោះ ចាប់ពីមួយខែកន្លះឡើងទៅឱ្យចេញមុនម៉ោង ១៥ នាទី ដោយរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ។

៣- សុំឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យស្ត្រីដែលសម្រាលកូនរួចចេញទៅបំបៅដោះកូនក្នុងមួយថ្ងៃមួយម៉ោង ពេលព្រឹកកន្លះម៉ោង និងពេលល្ងាចកន្លះម៉ោង ។

៤- នៅពេលកម្មករគ្រោះថ្នាក់ការងារសូមឱ្យក្រុមហ៊ុនទទួលខុសត្រូវទាំងស្រុងលើការព្យាបាល ហើយរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ផ្សេងៗ ។

៥- សុំឱ្យក្រុមហ៊ុនអនុវត្តការថែមម៉ោងឈរលើគោលការណ៍ស្ម័គ្រចិត្ត បើតម្រូវការថែមម៉ោងច្រើន សុំឱ្យក្រុមហ៊ុនរៀបចំម្ហូបអាហារឱ្យបានសមរម្យ ។

៦- សុំឱ្យក្រុមហ៊ុនរៀបចំបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកតំណាងកម្មករសាជាថ្មី ។

៧- សុំឱ្យក្រុមហ៊ុនរៀបចំកន្លែងដាក់កង់ម៉ូតូឱ្យបានគ្រប់គ្រាន់ ។

៨- សុំឱ្យក្រុមហ៊ុនសាងសង់ទារកដ្ឋាន និងបន្ទប់បំបៅដោះកូនតាមស្តង់ដារបស់ក្រសួង ។

៩- សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ភាគកម្មក្នុងប្រាក់ចំណេញជូនកម្មករ ។

១០- សុំឱ្យក្រុមហ៊ុនផ្តល់អាវភ្លៀង ២ សម្រាប់ដល់កម្មករក្នុងមួយរដូវកាល ជូនកម្មករក្នុងម្នាក់ ។

១១- សុំឱ្យក្រុមហ៊ុនផ្តល់ភាពងាយស្រួលដល់កម្មករ នៅពេលសុំច្បាប់នៅពេលសុំច្បាប់ឈប់សម្រាកមានធុរៈផ្សេងៗ ។

១២- នៅពេលកម្មករឡានខូច ឬម៉ូតូខូច មកយឺត សូមឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ផ្សេងៗ

១៣- សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលគោលជូនកម្មករម្តងម្កាលឱ្យស្មើនឹង ៩០ ដុល្លា និងសុំសងឡើងវិញចំពោះការផ្តល់មិនត្រឹមត្រូវកន្លងមក ។

១៤- សុំឱ្យក្រុមហ៊ុនតំឡើងប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ ដុល្លា ក្នុងមួយខែបន្ថែមទៀត ហើយនៅពេលក្រុមហ៊ុនតម្រូវការឱ្យកម្មករធ្វើការថ្ងៃបុណ្យ ថ្ងៃអាទិត្យ សុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួល ៥ ដុល្លា បន្ថែមទៀតក្នុងមួយថ្ងៃ ដែលក្រុមហ៊ុនបានផ្សព្វផ្សាយកន្លងមក ។

១៥- សុំឱ្យក្រុមហ៊ុនរៀបចំបន្ទប់ទឹកឱ្យមានអនាម័យ និងទឹកប្រើប្រាស់ឱ្យបានគ្រប់គ្រាន់ ព្រមទាំងកាផឹកទឹកក្នុងម្នាក់មួយ ។

១៦- សុំឱ្យក្រុមហ៊ុនបន្ថែមម៉ាស៊ីនស្អែនមេដៃមួយគ្រឿងទៀត ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩០ កប/ប្រក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ (អាណត្តិទី៧) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ២៦៨/១០ កប/កណ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ (វេលាម៉ោង ១៤:០០ នាទី រសៀល)

**កាលបរិច្ឆេទជួបប្រជុំក្រោយសវនាការ :** ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ (វេលាម៉ោង ១៤ : ៣០ នាទី រសៀល)

**បញ្ហានៃនីតិវិធី:**

នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលពាក្យបណ្តឹងរបស់សហជីពយុវជនខ្មែរ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមកមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះ ជាបន្តបន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១០ ដោយបាន

THE ARBITRATION COUNCIL

ទទួលលទ្ធផលមិនសះជាចំនួន ១៦ ចំណុចលើការទាមទារទាំងអស់ចំនួន ១៦ ចំណុច។ ចំណុចមិនសះជាចំនួន ១៦ ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ តាមរយៈរបាយការណ៍ដោះស្រាយវិវាទការងាររួមមិនសះជាលេខ ២៦៨/១០ ក.ប/កណ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ១៦ ចំណុចនេះ នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ (វេលាម៉ោង ១៤ : ០០ នាទីរសៀល)។ ភាគីក្រុមហ៊ុនអវត្តមាននៅថ្ងៃសវនាការនេះ ប៉ុន្តែបានស្នើសុំពន្យារសវនាការ ដោយឡែកភាគីកម្មករនិយោជិតមិនយល់ព្រមពន្យារពេលសវនាការឡើយ ហើយកម្មករនិយោជិតបានបំភ្លឺនៅក្នុងសវនាការថា ភាគីក្រុមហ៊ុនបានចាត់វិធានការវិវាទដែលធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ ដោយក្រុមហ៊ុនបានបញ្ឈប់ថ្នាក់ដឹកនាំសហជីពទាំងបីនាក់ពីការងារ នៅមុនថ្ងៃសវនាការមួយថ្ងៃ គឺថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១០ ហើយមិនអនុញ្ញាតឱ្យអ្នកទាំងបីចូលក្នុងក្រុមហ៊ុនទេ។ ថ្នាក់ដឹកនាំសហជីពទាំងបីនាក់ ដែលតំណាងឱ្យកម្មករនិយោជិតទាមទារក្នុងសំណុំរឿងនេះ និងដែលត្រូវបានបញ្ឈប់ពីការងារនោះមានប្រធានសហជីព អនុប្រធានសហជីព និងលេខាធិការសហជីព។ នៅក្នុងសវនាការនេះ ភាគីកម្មករនិយោជិតបានសំណូមពរឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញបញ្ជា បង្គាប់ឱ្យនិយោជកទទួលយកថ្នាក់ដឹកនាំសហជីពទាំងបីនាក់ចូលធ្វើការវិញ ដោយហេតុថា និយោជកបានចាត់វិធានការបញ្ឈប់បែបនេះ នៅក្នុងពេលដំណើរការអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យឃើញថា សកម្មភាពរបស់និយោជកក្នុងការបញ្ឈប់ថ្នាក់ដឹកនាំសហជីពទាំងអស់ ក្នុងអំឡុងពេលដំណើរការអាជ្ញាកណ្តាល ជាវិធានការដែលធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ ព្រោះកម្មករនិយោជិតបញ្ជាក់ថា ពួកគាត់គ្រោងនឹងធ្វើកូដកម្ម ដើម្បីឆ្លើយតបនឹងទង្វើបញ្ឈប់ថ្នាក់ដឹកនាំសហជីពនេះទៀតផង។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏បានសម្រេចចេញសេចក្តីបញ្ជាមួយនៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ បញ្ជាឱ្យនិយោជកទទួលយកថ្នាក់ដឹកនាំសហជីពទាំងបីនាក់ដែលនិយោជកបានបញ្ឈប់ពីការងារចូលធ្វើការវិញ។

ប៉ុន្តែ នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលលិខិតជំទាស់របស់ក្រុមហ៊ុនដែលបញ្ជាក់ថា ក្រុមហ៊ុនមិនអនុវត្តតាមបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ក្រុមហ៊ុនបញ្ជាក់ថា ការបញ្ឈប់ថ្នាក់ដឹកនាំសហជីពទាំងបីនាក់ខាងលើធ្វើឡើងទៅតាមច្បាប់ប៉ុណ្ណោះ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានកោះអញ្ជើញភាគីទាំងពីរមកបំភ្លឺលើបញ្ហានេះ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០។ ប៉ុន្តែ ភាគីទាំងពីរមិនបានចូលរួមតាមការកោះហៅរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ភាគីទាំងពីរសុំពន្យារពេលទៅពេលក្រោយ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនយល់ព្រមតាមការស្នើសុំពន្យារពេលបន្តទៀតទេ ព្រោះភាគីទាំងពីរមិនបានផ្តល់ដំណឹងឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល បានដឹងមុនអំពីហេតុផលសមរម្យ និងការចង់ពន្យារពេលនេះទេ រហូតដល់ម៉ោងកំណត់ត្រូវជួបបំភ្លឺបញ្ហាបញ្ឈប់ថ្នាក់ដឹកនាំសហជីពទាំងបីរូប លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទូរស័ព្ទទាក់ទង

THE ARBITRATION COUNCIL

ទើបភាគីទាំងពីរប្រាប់ថា សុំពន្យារពេល។ ហេតុនេះហើយ នៅក្នុងរឿងនេះក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណាដូចខាងក្រោម :

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក : គ្មាន**

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- លិខិតរបស់ប្រធាននាយកដ្ឋានវិវាទការងារលេខ ៤៤៣ កប/អក/វក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ ២០១០ ជម្រាបមកលោកប្រធានសហជីពយុវជនខ្មែរក្រុមហ៊ុន វីង យីង ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី ។

២- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពកយុវជនខ្មែរ លេខ ១៤៨៦ កប/វក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ ២០០៨ ។

៣- លិខិតរបស់សហព័ន្ធសហជីពយុវជនខ្មែរគោរពជូនលោកនាយកក្រុមហ៊ុន វីង យីង លេខ ២១៣ សសយខ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១០ ស្តីពីការជូនដំណឹងបោះឆ្នោតផ្លាស់ប្តូរគណៈកម្មាធិការសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន វីង យីង ។

៤- លិខិតរបស់សហព័ន្ធសហជីពយុវជនខ្មែរគោរពជូនលោកនាយកក្រុមហ៊ុន វីង យីង លេខ ១១២ សសយខ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១០ ស្តីពីការជូនដំណឹងបោះឆ្នោតផ្លាស់ប្តូរគណៈកម្មាធិការសហជីពយុវជនខ្មែរប្រចាំក្រុមហ៊ុន វីង យីង ។

៥- បង្កាន់ដៃសុំទទួលស្គាល់ថ្នាក់ដឹកនាំថ្មី ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន វីង យីង (ខេមបូឌា) លេខ ២៦៨/១០ កប/កណ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន វីង យីង (ខេមបូឌា) ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១០។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ២៥៩ កប/អក/វក/លកអ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ២៦០ កប/អក/វក/លកអ. ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មានលេខ ២៧៨ កប/អក/វក/លកអ. ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមផ្តល់ព័ត៌មានលេខ ២៧៩ កប/អក/វក/លកអ. ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១០។

## អង្គហេតុ

- មិនមានការរកឃើញអង្គហេតុទាក់ទងទៅនឹងចំណុចបញ្ហាវិវាទ នៅក្នុងរបាយការណ៍មិនសះជា ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល មិនអាចដំណើរការទៅបាន ។
- នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ ភាគីកម្មករនិយោជិតបានសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលបិទសំណុំរឿងនេះ ដូចជាករណីដែលកម្មករនិយោជិតធ្វើកូដកម្មក្នុងអំឡុងពេលដំណើរការអាជ្ញាកណ្តាលដែរ ដោយហេតុថា និយោជកមិនគោរពតាមច្បាប់ស្តីពីការងារ ហើយចាត់វិធានការបញ្ឈប់ថ្នាក់ដឹកនាំសហជីពក្នុងអំឡុងពេលដំណើរការអាជ្ញាកណ្តាល ដែលធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ ។

## ហេតុផលនៃសេចក្តីសម្រេចៈ

ប្រការ ២០ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចែងថា *"ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជា កូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម ។"*

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ខាងលើក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជា កូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ។

នៅក្នុងសំណុំរឿងនេះ ភាគីនិយោជក មិនមានវត្តមានតាមការកោះហៅរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលម្តងជាពីរដង ដើម្បីចូលរួមដោះស្រាយបញ្ហាវិវាទនៅក្នុងសំណុំរឿងនេះទេ។ ម្យ៉ាងទៀតភាគីនិយោជក ក៏មិនគោរពតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ឱ្យនិយោជកបញ្ឈប់រាល់វិធានការដែលធ្វើឱ្យស្ថានភាព

វិវាទកាន់តែធ្ងន់ធ្ងរ ពិសេសលើករណីបញ្ឈប់ថ្នាក់ដឹកនាំសហជីពទាំងអស់ពីការងារ នៅក្នុងអំឡុងពេលដំណើរការអាជ្ញាកណ្ដាល។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ព្យាយាមកោះហៅភាគីទាំងពីរ ដើម្បីមកបំភ្លឺលើបញ្ហាការបង្កឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០។ ប៉ុន្តែ ភាគីទាំងពីរមិនបានចូលរួមតាមការកោះហៅរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទេ។ លើសពីនេះទៅទៀត កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ ភាគីកម្មករនិយោជិតបានសំណូមពរមកកាន់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលឱ្យបិទសំណុំរឿង មិនបន្តនីតិវិធីអាជ្ញាកណ្ដាល ដូចករណីដែលកម្មករនិយោជិតធ្វើកូដកម្មក្នុងអំឡុងពេលដំណើរការអាជ្ញាកណ្ដាលដែរ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាល សម្រេចមិនបន្តដំណើរការអាជ្ញាកណ្ដាលក្នុងសំណុំរឿងនេះទេ។

យោងតាមហេតុផលខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចដូចតទៅ :

## សម្រេច

មិនបន្តដំណើរការអាជ្ញាកណ្ដាលក្នុងសំណុំរឿងលេខ ៤៩/១០-វិង យីង នេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : អ៊ុំ សុន្ធី

ហត្ថលេខា: ------------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : លីម សុវណ្ណា

ហត្ថលេខា: ------------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល :

ឈ្មោះ : គង់ ផល្លះ

ហត្ថលេខា: ------------------------------------